ម៉ាស៊ីនបោះពុម្ពឡាស៊ែរសខ្មៅ · WI-FI

MTC NP2900W

សៀវភៅណែនាំ

មាតិកា

1 ស្គាល់ម៉ាស៊ីនបោះពុម្ព 4

1.1 អ្វីដែលមានក្នុងប្រអប់ 4
1.2 ការពន្លាប្រអប់ 5
1.3 ការដាក់ប្រអប់ទឹកថ្នាំ 5
1.4 ការបើកម៉ាស៊ីន 6
1.5 ការដាក់ក្រដាស 7
1.6 ការបោះពុម្ពទំព័រសាកល្បង 7
1.7 ភ្លើងសញ្ញា និងប៊ូតុង PAPER 8

2 ការភ្ជាប់ Wi-Fi លើកដំបូង 9

2.1 ចូលបណ្តាញផ្ទាល់របស់ម៉ាស៊ីនបោះពុម្ព 9
2.2 ជ្រើស Wi-Fi ការិយាល័យ 10

3 Windows 12

3.1 ទាញយកកម្មវិធីដំឡើង 12
3.2 ដំឡើង 12
3.3 ចាប់ផ្តើមលើកដំបូង៖ ជ្រើសម៉ាស៊ីនបោះពុម្ព 15
3.4 ការបោះពុម្ពពី Word, Excel, PDF និងកម្មវិធីផ្សេងៗ 17
3.5 បោះពុម្ពឯកសារ៖ PDF, រូបភាព, Word, Excel 19
3.6 តាមដានការបោះពុម្ព និងការជូនដំណឹង 20
3.7 ការបោះពុម្ពតាម USB 22
3.8 ការបោះពុម្ពពីខាងក្រៅ 23
3.9 ប្តូរឈ្មោះម៉ាស៊ីន 24
3.10 ធ្វើបច្ចុប្បន្នភាពកម្មវិធីម៉ាស៊ីន 25
3.11 ការកំណត់ 27

4 macOS 28

4.1 ទាញយកកម្មវិធីដំឡើង 28
4.2 ដំឡើង 28
4.3 ចាប់ផ្តើមលើកដំបូង៖ ជ្រើសម៉ាស៊ីនបោះពុម្ព 29
4.4 ការបោះពុម្ពពីកម្មវិធីផ្សេងៗ 30
4.5 បោះពុម្ពឯកសារ៖ PDF, រូបភាព, Word, Excel 31
4.6 តាមដានការបោះពុម្ព និងការជូនដំណឹង 32
4.7 ការបោះពុម្ពតាម USB 33
4.8 ការបោះពុម្ពពីខាងក្រៅ 33
4.9 ការកំណត់ និងបច្ចុប្បន្នភាព 35

5 Android 36

5.1 ទាញយកកម្មវិធី 36
5.2 បើកកម្មវិធី ហើយជ្រើសម៉ាស៊ីនបោះពុម្ព 37
5.3 ការបោះពុម្ពពីកម្មវិធីផ្សេងៗ 38
5.4 បោះពុម្ពឯកសារ៖ PDF, រូបភាព, Word, Excel 39
5.5 តាមដានការបោះពុម្ព និងការជូនដំណឹង 40
5.6 ការបោះពុម្ពពីខាងក្រៅ 41
5.7 ការកំណត់ និងបច្ចុប្បន្នភាព 43

6 iPhone និង iPad 44

6.1 ទាញយកកម្មវិធី 44
6.2 បើកកម្មវិធី ហើយជ្រើសម៉ាស៊ីនបោះពុម្ព 44
6.3 ការបោះពុម្ពពីកម្មវិធីផ្សេងៗ 45
6.4 បោះពុម្ពឯកសារ៖ PDF, រូបភាព, Word, Excel 46
6.5 តាមដានការបោះពុម្ព និងការជូនដំណឹង 47
6.6 ការបោះពុម្ពពីខាងក្រៅ 48
6.7 ការកំណត់ និងបច្ចុប្បន្នភាព 50

7 ឯកសារយោង និងការដោះស្រាយបញ្ហា 51


7.1 ការបោះពុម្ពដោយគ្មាន Wi-Fi ការិយាល័យ 51
7.2 ពេលមានបញ្ហា 52
7.3 ជំនួយបន្ថែម 52

1


ស្គាល់ម៉ាស៊ីនបោះពុម្ព

ពន្លាប្រអប់ ដាក់ប្រអប់ទឹកថ្នាំ ដោតភ្លើង ដាក់ក្រដាស បោះពុម្ពទំព័រសាកល្បង។

1.1 អ្វីដែលមានក្នុងប្រអប់



ម៉ាស៊ីនបោះពុម្ព NP2900W




ប្រអប់ទឹកថ្នាំ ក្នុងថង់



ខ្សែភ្លើង



ខ្សែ USB



ស៊ីឌីកម្មវិធីបញ្ជា



ការណែនាំចាប់ផ្តើមរហ័ស


- ដាក់ម៉ាស៊ីនលើផ្ទៃរឹង និងរាបស្មើ មានកន្លែងទំនេរខាងមុខសម្រាប់បើកថាស (13 សម បន្ថែម) និងខាងលើសម្រាប់ថាសទទួលក្រដាស។
- ឆ្ងាយពីជញ្ជាំងយ៉ាងហោចណាស់ 10 សម កុំបិទរន្ធខ្យល់នៅខាងក្រោយ។
- នៅក្នុងដែនសញ្ញា Wi-Fi ការិយាល័យ ឆ្ងាយពីពន្លឺថ្ងៃ សំណើម ធូលី និងកំដៅ។
- ជិតព្រីភ្លើង 220–240 V ដែលមានខ្សែដី។

ចំណាំ


ប្រើតែខ្សែភ្លើងដែលភ្ជាប់មកជាមួយម៉ាស៊ីនបោះពុម្ពប៉ុណ្ណោះ។ កុំបើកគម្របតួម៉ាស៊ីន។

1.2 ការពន្លាប្រអប់

1. លើកម៉ាស៊ីនបោះពុម្ពចេញពីប្រអប់ដោយដៃទាំងពីរ ដោយកាន់នៅចំហៀងម៉ាស៊ីន។
2. ដកស្រទាបការពារទាំងអស់ចេញពីផ្នែកខាងក្រៅម៉ាស៊ីនបោះពុម្ព។
3. បត់ថាសពហុមុខងារចុះ ហើយដកបន្ទះក្រដាសកាតុងចេញ។ បើកគម្របខាងលើ ហើយដកសម្ភារៈវេចខ្ចប់ខាងក្នុងចេញ។



ដកស្រទាបចេញទាំងអស់




ដកបន្ទះក្រដាសកាតុងចេញ

គន្លឹះ


ម៉ាស៊ីនបោះពុម្ពមានទម្ងន់ប្រហែល 5.7 គីឡូក្រាម។ កុំលើកវាដោយកាន់ថាសក្រដាស ឬគម្របខាងលើ។

1.3 ការដាក់ប្រអប់ទឹកថ្នាំ

1. លើកថាសទទួលក្រដាសឡើង បន្ទាប់មកបើកគម្របខាងលើ៖ កាន់ដៃចាប់នៅខាងស្តាំគម្រប ហើយលើកឡើងរហូតដល់វាឈប់។




2. យកប្រអប់ទឹកថ្នាំចេញពីថង់។ កាន់វាឱ្យស្មើ ហើយអង្រួនថ្នមៗ 5–6 ដង ដើម្បីឱ្យម្សៅទឹកថ្នាំរាយស្មើ។
3. ដាក់ប្រអប់ទឹកថ្នាំលើផ្នែករាបស្មើ ហើយទាញស្តុតបិទជិតចេញត្រង់ៗ យឺតៗ រហូតដល់វារបូតចេញទាំងស្រុង (ប្រហែល 50 សម)។ កុំប៉ះគម្របស៊ីឡាំងនៅខាងក្រោម។




អង្រួនថ្មមៗ 5–6 ដង | ទាញស្លាកបិទជិតចេញត្រង់ៗ | កុំប៉ះ ឬបើកគម្របស៊ីឡាំង

4. កាន់ប្រអប់ទឹកថ្នាំត្រង់ដៃចាប់ បញ្ចូលចុងទាំងពីរទៅក្នុងរន្ធណែនាំក្នុងម៉ាស៊ីនបោះពុម្ព ហើយរុញថ្នមៗរហូតដល់វាជាប់ណែន។
5. បិទគម្របខាងលើ។




1.4 ការបើកម៉ាស៊ីន

1. ដោតខ្សែភ្លើងទៅរន្ធនៅខាងក្រោយម៉ាស៊ីនបោះពុម្ព ខាងឆ្វេង។ ដោតចុងម្ខាងទៀតទៅព្រីភ្លើងដែលមានខ្សែដី។
2. បើកកុងតាក់ទៅ I។ ភ្លើង Power ភ្លឺពណ៌ខៀវ។ ភ្លើងស្ថានភាពភ្លឹបភ្លែតពណ៌បៃតងយឺតៗ (ភ្លឺ 1 វិនាទី រលត់ 1 វិនាទី)៖ ម៉ាស៊ីនបោះពុម្ព កំពុងរង់ចាំភ្ជាប់ Wi-Fi (ជំពូក 2)។



1.5 ការដាក់ក្រដាស


1. បត់ថាសពហុមុខងារចុះ ហើយទាញឧបករណ៍ណែនាំខាងក្រោយចេញ។
2. ដាក់ក្រដាស**ផ្នែបោះពុម្ពផ្ងារឡើង** ជ្រុងខ្លីចូលមុន ហើយរុញថ្នមៗរហូតដល់វាឈប់។ ក្រដាសត្រូវនៅក្រោមសញ្ញាកំណត់ទាំងសងខាង។
3. រុញឧបករណ៍ណែនាំឱ្យជាប់គែមក្រដាស ដោយមិនច្របាច់ក្រដាស។
4. លើកថាសទទួលក្រដាសឡើង ដើម្បីទទួលក្រដាសដែលបោះពុម្ពចេញ។



ថាសពហុមុខងារដាក់ក្រដាសធម្មតាបានប្រហែល 150 សន្លឹក 64–90 g/m²។

1.6 ការបោះពុម្ពទំព័រសាកល្បង

ពេលម៉ាស៊ីនបោះពុម្ពទំនេរ សង្កត់ប៊ូតុង **PAPER** ជាប់ប្រហែល 3 វិនាទី រហូតដល់ភ្លើង Power ភ្លឹបភ្លែត ហើយលែងវិញ។ ទំព័រសាកល្បងបង្ហាញថាម៉ាស៊ីនដំណើរការ ហើយប្រាប់ឈ្មោះបណ្តាញ Wi-Fi របស់ម៉ាស៊ីន (**NP2900W-XXXX**) និងជំហានភ្ជាប់ Wi-Fi។



គន្លឹះ

XXXX គឺជាតួអក្សរ 4 ដែលខុសគ្នាសម្រាប់ម៉ាស៊ីននីមួយៗ។ អ្នកត្រូវការវានៅជំពូក 2។

1.7 ភ្លើងសញ្ញា និងប៊ូតុង PAPER

ម៉ាស៊ីនបោះពុម្ពមានភ្លើងពីរ៖ ភ្លើង Power (ពណ៌ខៀវ) បង្ហាញថាម៉ាស៊ីនកំពុងធ្វើអ្វី ភ្លើងស្ថានភាព (បៃតង ឬក្រហម) បង្ហាញស្ថានភាព Wi-Fi និងអ្វីដែលម៉ាស៊ីនត្រូវការឱ្យអ្នកធ្វើ។ ភ្លើងស្ថានភាពរលត់គឺជារឿងធម្មតា។

ភ្លើង	អត្ថន័យ
Power ភ្លឺជាប់	បើក ទំនេរ ឬកំពុងបោះពុម្ព។
Power ភ្លឹបភ្លែតយឺតៗ	មានការបោះពុម្ពកំពុងរង់ចាំវេន។
Power ភ្លឹបភ្លែតលឿនខ្លាំង	កំពុងធ្វើបច្ចុប្បន្នភាពកម្មវិធីម៉ាស៊ីន៖ កុំបិទវា។
បៃតង ភ្លឹបខ្លីៗរៀងរាល់ 3 វិនាទី	បានភ្ជាប់ Wi-Fi ការិយាល័យ។
បៃតង ភ្លឹបញាប់	កំពុងទទួលឯកសារដើម្បីបោះពុម្ព។
បៃតង ភ្លឹបភ្លែតលឿន	កំពុងភ្ជាប់ Wi-Fi។
បៃតង ភ្លឺ 1 វិនាទី រលត់ 1 វិនាទី	មិនទាន់ភ្ជាប់ Wi-Fi រង់ចាំការរៀបចំ (ជំពូក 2)។
ក្រហម ភ្លឹបភ្លែតជាប់ៗ	អស់ក្រដាស៖ ដាក់ក្រដាស ចុចប៊ូតុង PAPER។
ក្រហម ភ្លឺជាប់	គម្របខាងលើបើក៖ បិទវា។
ក្រហម ភ្លឹបជាក្រុម ក្រុមមួយ 2 ដង	ក្រដាសស្ទះ៖ បើកគម្របខាងលើ ដកប្រអប់ទឹកថ្នាំចេញ ទាញក្រដាសចេញថ្នមៗ។
ក្រហម ភ្លឹបជាក្រុម ក្រុមមួយ 3 ដង	រកមិនឃើញប្រអប់ទឹកថ្នាំ៖ ដាក់វាចូលវិញតាមរន្ធណែនាំ។

ប៊ូតុង PAPER	មុខងារ
ចុចម្តង	បន្តបោះពុម្ពក្រោយដាក់ក្រដាស។
សង្កត់ 3 វិនាទី រួចលែង	បោះពុម្ពទំព័រសាកល្បង (ភ្លើង Power ភ្លឹបនៅវិនាទីទី 3)។
សង្កត់ 8 វិនាទី រួចលែង	លុបការកំណត់ Wi-Fi៖ ម៉ាស៊ីនត្រឡប់ទៅបណ្តាញ NP2900W-XXXX វិញ ដើម្បីរៀបចំម្តងទៀត (ជំពូក 2)។ ភ្លើង Power ភ្លឹបលឿននៅវិនាទីទី 8។

2


ការភ្ជាប់ Wi-Fi លើកដំបូង

ធ្វើតែម្តង ដោយប្រើទូរស័ព្ទ។ ចំណាយពេលប្រហែល 2 នាទី។

ម៉ាស៊ីនភ្ជាប់ Wi-Fi ការិយាល័យ ឬផ្ទះរបស់អ្នក ដើម្បីឱ្យកុំព្យូទ័រ និងទូរស័ព្ទទាំងអស់នៅលើបណ្តាញនោះបោះពុម្ពបាន។ iPhone ឬ Android ណាក៏បាន រូបភាពបង្ហាញ iPhone។

2.1 ចូលបណ្តាញផ្ទាល់របស់ម៉ាស៊ីនបោះពុម្ព

បើកម៉ាស៊ីនបោះពុម្ព ហើយរង់ចាំភ្លើងស្ថានភាពភ្លឺបពណ៌បៃតងយឺតៗ។ នៅលើទូរស័ព្ទ បើក **Settings** → **Wi-Fi**៖




1. ចុចបណ្តាញ **NP2900W-XXXX**។ វាគ្មានពាក្យសម្ងាត់។ ទំព័ររៀបចំរបស់ម៉ាស៊ីនបើកដោយខ្លួនឯង បើមិនបើក សូមបើកកម្មវិធីរុករក ហើយចូលទៅ **192.168.4.1**។

គន្លឹះ

ទូរស័ព្ទ Android បង្ហាញ “ចូលបណ្តាញ” ឬ “គ្មានអ៊ីនធឺណិត”៖ ចុចការជូនដំណឹងដើម្បីបើកទំព័ររៀបចំ ឬជ្រើសនៅភ្ជាប់ដដែល។

2.2 ជ្រើស Wi-Fi ការិយាល័យ

ទំព័ររៀបចំរបស់ម៉ាស៊ីនបោះពុម្ព៖



1. ចុចឈ្មោះ Wi-Fi ការិយាល័យ។
2. វាយពាក្យសម្ងាត់ Wi-Fi។
3. ចុច **Connect**។
4. ទំព័របង្ហាញ **Now watch the printer's green light**។ មើលភ្លើងស្ថានភាពលើម៉ាស៊ីនបោះពុម្ព៖

ភ្លើងបៃតង	មានន័យថា
ភ្លឹបភ្លែតលឿន	កំពុងភ្ជាប់ អាចចំណាយពេលរហូតដល់ 1 នាទី។
ភ្លឺ 3 វិនាទី បន្ទាប់មកភ្លឹបខ្លីៗរៀងរាល់ 3 វិនាទី	បានភ្ជាប់។ រួចរាល់!
ភ្លឹបភ្លែតយឺតៗ (ភ្លឺ 1 វិនាទី រលត់ 1 វិនាទី)	មិនបានភ្ជាប់។ ពិនិត្យពាក្យសម្ងាត់ ហើយចាប់ផ្តើមម្តងទៀតពី 2.1។

គន្លឹះ

ម៉ាស៊ីនបោះពុម្ពប្រើ Wi-Fi 2.4 GHz៖ បណ្តាញដែលមានតែ 5 GHz នឹងមិនបង្ហាញក្នុងបញ្ជីទេ។ បណ្តាញដែលសម្គាល់ថា “សញ្ញាខ្សោយ” នៅឆ្ងាយពេក៖ ដាក់ម៉ាស៊ីនបោះពុម្ពឱ្យជិតរ៉ោតទ័រ Wi-Fi។

បន្ទាប់មក ឱ្យទូរស័ព្ទត្រឡប់ទៅ Wi-Fi ការិយាល័យវិញ ហើយដំឡើងកម្មវិធី MTC នៅលើឧបករណ៍ដែលអ្នកបោះពុម្ព៖ Windows (ជំពូក 3) macOS (ជំពូក 4) Android (ជំពូក 5) iPhone និង iPad (ជំពូក 6)។

គន្លឹះ

ក្រោយរៀបចំរួច បណ្តាញផ្ទាល់របស់ម៉ាស៊ីនក្លាយជា **NP2900W-XXXX Direct** (ឬ **<ឈ្មោះម៉ាស៊ីន> Direct** ពេលម៉ាស៊ីនមានឈ្មោះ) ពាក្យសម្ងាត់ **1234567890**។ វាសម្រាប់បោះពុម្ពដោយគ្មាន Wi-Fi ការិយាល័យ (7.1)។

3

Windows

កម្មវិធី MTC NP2900W Driver បន្ថែមម៉ាស៊ីនបោះពុម្ពទៅ Windows 10 និង 11 រកវានៅលើបណ្តាញ និងបង្ហាញថាការបោះពុម្ពនីមួយៗនៅដល់ណា។


3.1 ទាញយកកម្មវិធីដំឡើង

នៅលើកុំព្យូទ័រ បើក **mtcprinter.com** → **ផលិតផល** → **NP2900W** → ផ្ទាំង **កម្មវិធីបញ្ជា និងបច្ចុប្បន្នភាព** ហើយចុច **ទាញយក** នៅបន្ទាត់ Windows។ ឯកសារមានឈ្មោះប្រហែល **MTC_NP2900W_Driver_Setup_2.4.3.exe** (កំណែអាចថ្មីជាងនេះ) ហើយនៅក្នុងថត **Downloads**។

3.2 ដំឡើង

បើកឯកសារដែលបានទាញយក។ បើ Windows បង្ហាញអេក្រង់ពណ៌ខៀវ **Windows protected your PC**៖







1. ចុច **More info**។
2. ចុច **Run anyway**។

គន្លឹះ


អេក្រង់នេះបង្ហាញ ព្រោះកម្មវិធីដំឡើងមិនទាន់ត្រូវបានចុះហត្ថលេខាជាមួយ Microsoft។ កម្មវិធីដំឡើងពី mtcprinter.com គឺជារបស់ពិតពី MTC។






3 ចុច **Next**។ ដើម្បីមានរូបតំណាងលើផ្ទៃតុ សូមទុក **Create a desktop shortcut** ឱ្យធីក។


4 ចុច **Install**។





5 កម្មវិធីដំឡើងបន្ថែមម៉ាស៊ីនបោះពុម្ព **MTC NP2900W** ទៅ Windows។

6 Windows សុំការអនុញ្ញាត៖ ចុច **Yes**។



7 ទុក **Launch MTC NP2900W Driver** ឱ្យធីក ហើយចុច **Finish**។


គន្លឹះ

ឥឡូវ Windows មានម៉ាស៊ីនបោះពុម្ព **MTC NP2900W** ហើយ។ កម្មវិធីចាប់ផ្តើមជាមួយ Windows ហើយនៅក្នុងថាសប្រព័ន្ធ ខាងក្រោមស្តាំអេក្រង់។


3

3.3 ចាប់ផ្តើមលើកដំបូង៖ ជ្រើសម៉ាស៊ីនបោះពុម្ព

កម្មវិធីបើកជាភាសារបស់ Windows។ ដើម្បីប្តូរ៖




1. ចុចប្រអប់ភាសានៅខាងលើស្តាំ។
2. ជ្រើសភាសារបស់អ្នក។



3 ចុចប្រអប់ **Current printer**។ កម្មវិធីស្វែងរកម៉ាស៊ីនបោះពុម្ពនៅលើបណ្តាញ។

4 ចុចឈ្មោះម៉ាស៊ីនបោះពុម្ពរបស់អ្នក។ បើមិនមានក្នុងបញ្ជី៖ មើលជំពូក 2 ម៉ាស៊ីនបោះពុម្ពត្រូវនៅលើបណ្តាញ Wi-Fi ដូចកុំព្យូទ័រ។



5. បន្ទាត់បៃតង **Ready to print over Wi-Fi**៖ អ្នកអាចបោះពុម្ពបាន។


6. **Print a file**៖ PDF រូបភាព Word Excel ទោះគ្មាន Office នៅលើកុំព្យូទ័រក៏ដោយ (3.5)។

គន្លឹះ៖

កម្មវិធីចងចាំម៉ាស៊ីនដែលបានជ្រើស។ ចាប់ពីពេលនេះ បោះពុម្ពពីកម្មវិធីណាក៏បាន ហើយជ្រើសម៉ាស៊ីន **MTC NP2900W**។

3.4 ការបោះពុម្ពពី Word, Excel, PDF និងកម្មវិធីផ្សេងៗ


បោះពុម្ពដូចធម្មតា៖ ចុច **Ctrl+P** ជ្រើសម៉ាស៊ីន **MTC NP2900W** ហើយចុច **Print**។ ខាងក្រោមគឺជាបង្ហួចបោះពុម្ពរបស់ Microsoft Edge សម្រាប់ PDF កម្មវិធីផ្សេងៗមានបង្ហួចផ្ទាល់ខ្លួន ដែលមានប្រអប់ជ្រើសម៉ាស៊ីនដូចគ្នា។



1. ជ្រើសម៉ាស៊ីន **MTC NP2900W**។

2. ចុច **Print**។

បង្ហួច **MTC NP2900W Driver** បើកដោយខ្លួនឯង ហើយបង្ហាញថាការបោះពុម្ពនៅដល់ណា៖




3. ម៉ាស៊ីនកំពុងបោះពុម្ពឯកសាររបស់អ្នក៖ ឈ្មោះ និងទំព័រដែលកំពុងបោះពុម្ព។
4. **Cancel**៖ បញ្ឈប់ការបោះពុម្ពនេះ។
5. **Printer queue**៖ ការបោះពុម្ពដែលកំពុងរង់ចាំ របស់អ្នក និងរបស់អ្នកដទៃដែលប្រើម៉ាស៊ីន។

គន្លឹះ

ពេលកុំព្យូទ័រ និងទូរស័ព្ទច្រើនបោះពុម្ពក្នុងពេលតែមួយ ម៉ាស៊ីនរៀបជាជួរ ហើយបោះពុម្ពតាមវេន គ្មានអ្វីបាត់ទេ។

3.5 បោះពុម្ពឯកសារ៖ PDF, រូបភាព, Word, Excel

ចុច **Print a file** នៅផ្នាំង **Status** ហើយជ្រើសឯកសារ។ PDF រូបភាព Word និង Excel បោះពុម្ពបាន ទោះគ្មាន Office នៅលើកុំព្យូទ័រក៏ដោយ។




1. ការមើលជាមុនសខ្មៅ ដូចក្រដាសដែលនឹងចេញមក។ ចុច ✓ លើទំព័រណាមួយ ដើម្បីរំលង ឬរក្សាវា។
2. ម៉ាស៊ីនបោះពុម្ព។ បើមានច្រើន អ្នកអាចជ្រើសច្រើនជាងមួយ ដើម្បីបោះពុម្ពជាមួយគ្នា។
3. ទំព័រ៖ ទាំងអស់ សេស គូ ឬវាយចន្លោះទំព័រ ដូចជា **1-5, 8**។ បោះពុម្ពទំព័រសេសមុន បន្ទាប់មកទំព័រគូ ដើម្បីបោះពុម្ពពីរមុខដោយដៃ។
4. ចំនួនច្បាប់ ទំហំក្រដាស ទិសដៅ។
5. **Print options**៖ ភាពដិត បង្រួមទំព័រគ្មានគែមឱ្យសម។ សម្រាប់ការបោះពុម្ពនេះតែប៉ុណ្ណោះ។
6. ចុច **Print**។


គន្លឹះ

ឯកសារ Word និង Excel ត្រូវបានរៀបចំនៅលើកុំព្យូទ័ររបស់អ្នកផ្ទាល់ ហើយមិនត្រូវបានផ្ញើទៅណាទេ។ ជាមួយ Excel អ្នកអាចជ្រើសសន្លឹក ហើយបង្រួមសន្លឹកនីមួយៗឱ្យសមមួយទំព័រ។

3.6 តាមដានការបោះពុម្ព និងការជូនដំណឹង




1 ☰: ការបោះពុម្ពមិនទាន់ចប់របស់កុំព្យូទ័រនេះ តាមម៉ាស៊ីន។ អាចបោះបង់ម្តងមួយៗ។



2 **Bell**៖ បានបោះពុម្ព អស់ក្រដាស ក្រដាសស្ទះ... ចំណុចពណ៌ស្វាយសម្គាល់ការជូនដំណឹងមិនទាន់អាន។

3.7 ការបោះពុម្ពតាម USB


កុំព្យូទ័រមិននៅលើបណ្តាញរបស់ម៉ាស៊ីន ឬគ្មាន Wi-Fi៖ ភ្ជាប់ខ្សែ USB ដែលភ្ជាប់មកជាមួយម៉ាស៊ីនទៅកុំព្យូទ័រ។ គ្មានអ្វីត្រូវដំឡើងបន្ថែម៖ កម្មវិធីធ្វើការបោះពុម្ពតាមខ្សែ។




1. **Ready to print over USB**៖ អ្នកអាចបោះពុម្ពបាន។
2. **USB cable: Connected**។


3.8 ការបោះពុម្ពពីខាងក្រៅ

អនុញ្ញាតឱ្យកុំព្យូទ័រ និងទូរស័ព្ទនៅកន្លែងផ្សេងបោះពុម្ពមកម៉ាស៊ីននេះតាម MTC Cloud។ នៅលើកុំព្យូទ័រដែលនៅលើបណ្តាញរបស់ម៉ាស៊ីន បើកផ្ទាំង **Printer** ហើយរំកិលចុះទៅ **Printing from outside**៖




1. បើក **Printing from outside**។
2. ចុច **Share this printer**។





3. ជ្រើសរយៈពេលដែលពួកគេអាចបោះពុម្ព៖ 15 នាទី 1 ម៉ោង 1 ខែ ឬជារៀងរហូត។
4. ចុច **Create the QR code**។
5. ម្នាក់ទៀតស្កេនកូដដោយកាមេរ៉ាទូរស័ព្ទ ឬអ្នកធ្វើតំណទៅគេ។ កូដប្រើបានតែម្តង ក្នុងរយៈពេល 1 នាទី។

នៅលើកុំព្យូទ័រ Windows នៅកន្លែងផ្សេងដែលមាន MTC NP2900W Driver៖ គ្រាន់តែបើកតំណអញ្ជើញ។ ឬចុចប្រអប់ **Current printer** → **Add a printer with an invitation link** បិទភ្ជាប់តំណ ហើយចុច **Add**។





6. បិទភ្ជាប់តំណអញ្ជើញ។
7. ចុច **Add**។

គន្លឹះ

ម៉ាស៊ីនមួយទទួលឧបករណ៍បោះពុម្ពពីខាងក្រៅបានរហូតដល់ 10។ ក្នុងបញ្ជី **Devices that print from outside** អ្នកអាចពន្យារដកចេញ ឬបិទឧបករណ៍នីមួយៗ។

3.9 ប្តូរឈ្មោះម៉ាស៊ីន







1. នៅផ្នាំង **Printer** ចុចរូបខ្មៅដៃ។
2. វាយឈ្មោះថ្មី រហូតដល់ 32 តួអក្សរ ហើយចុច **Save**។ ឈ្មោះត្រូវបានរក្សាទុកក្នុងម៉ាស៊ីន៖ កុំព្យូទ័រ និងទូរស័ព្ទទាំងអស់ឃើញវា។

3.10 ធ្វើបច្ចុប្បន្នភាពកម្មវិធីម៉ាស៊ីន

ពេលមានកំណែថ្មី ផ្ទាំង **Printer** មានចំណុចពណ៌ស្វាយ ហើយបន្ទាត់ **Firmware** បង្ហាញលេខកំណែថ្មី។



1 ចុច **Update**។




2 កម្មវិធីទាញយកកំណែថ្មី ហើយផ្ញើទៅម៉ាស៊ីនតាម Wi-Fi ឬខ្សែ USB បន្ទាប់មកម៉ាស៊ីនចាប់ផ្តើមឡើងវិញដោយខ្លួនឯង។

ចំណាំ

កុំបិទម៉ាស៊ីនពេលកំពុងធ្វើបច្ចុប្បន្នភាព។ កម្មវិធី MTC NP2900W Driver ធ្វើបច្ចុប្បន្នភាពខ្លួនឯងពេលមានកំណែថ្មី។

3.11 ការកំណត់



1. **Printer in Windows**៖ ដំឡើងឡើងវិញ ឬដកម៉ាស៊ីន “MTC NP2900W” ចេញពី Windows។
2. **Open this window by itself**៖ រាល់ពេលបោះពុម្ព ឬតែពេលមានបញ្ហា។
3. **Page position** និង **Print darkness**៖ កែតម្រូវពេលការបោះពុម្ពមិននៅកណ្តាល ឬស្រាលពេក។

4

macOS


កម្មវិធី MTC NP2900W សម្រាប់ Mac ដែលប្រើ macOS 13 ឬថ្មីជាងនេះ ឈីប Apple silicon ឬ Intel។

4.1 ទាញយកកម្មវិធីដំឡើង

បើក **mtcprinter.com** → **ផលិតផល** → **NP2900W** → ផ្ទាំង **កម្មវិធីបញ្ជា និងបច្ចុប្បន្នភាព** ហើយចុច **ទាញយក** នៅបន្ទាត់ macOS៖ Mac ឈីប Apple silicon (M1, M2…) ប្រើកំណែ **arm64** Mac ឈីប Intel ប្រើ **x86_64**។ ដើម្បីដឹង៖ ម៉ឺនុយ Apple → **About This Mac**។ ឯកសារមានឈ្មោះប្រហែល **MTC_NP2900W_macOS_2.4.3_arm64.pkg** ហើយនៅក្នុងថត **Downloads**។


4.2 ដំឡើង

បើកឯកសារដែលបានទាញយក។ កម្មវិធីដំឡើងមិនទាន់ត្រូវបានបញ្ជាក់ដោយ Apple ដូច្នេះ macOS បញ្ឈប់វានៅលើកដំបូង៖



1. ចុច **Done**។
2. បើក **System Settings** → **Privacy & Security** រំកិលចុះ ហើយចុច **Open Anyway**។ បញ្ចូលពាក្យសម្ងាត់ Mac បន្ទាប់មកចុច **Open Anyway** ម្តងទៀត។

កម្មវិធីដំឡើងបើក៖




3. ចុច **Continue** បន្ទាប់មក **Install**។
4. បញ្ចូលពាក្យសម្ងាត់ Mac ហើយចុច **Install Software**។
5. ពេលរួចរាល់ ចុច **Close**។


គន្លឹះ

កម្មវិធីដំឡើងបន្ថែមម៉ាស៊ីន **MTC NP2900W** ទៅ macOS ហើយបើកកម្មវិធី។ កម្មវិធីនៅក្នុងរបារម៉ឺនុយ (ខាងលើស្តាំអេក្រង់) ហើយចាប់ផ្តើមជាមួយ Mac៖ ចុចរូបតំណាងរបស់វា → **Open** ដើម្បីបង្ហាញបង្អួច។


4.3 ចាប់ផ្តើមលើកដំបូង៖ ជ្រើសម៉ាស៊ីនបោះពុម្ព

កម្មវិធីប្រើភាសារបស់ Mac ដើម្បីប្តូរ ចុចប៊ូតុងភាសានៅខាងលើស្តាំ។ លើកដំបូង ចូលទៅផ្ទាំង **Printer**៖





1. ចុចប្រអប់ **Current printer**។
2. ចុចឈ្មោះម៉ាស៊ីនរបស់អ្នក។ គ្មានម៉ាស៊ីន៖ Mac ត្រូវនៅលើបណ្តាញ Wi-Fi របស់ម៉ាស៊ីន ឬភ្ជាប់ខ្សែ USB (4.7)។




3 **Ready to print over Wi-Fi**៖ អ្នកអាចបោះពុម្ពបាន។

4 **Print a file** (4.5)។

4.4 ការបោះពុម្ពពីកម្មវិធីផ្សេងៗ

បោះពុម្ពដូចធម្មតា៖ ចុច **⌘P** (ឬ **File** → **Print**) ជ្រើសម៉ាស៊ីន **MTC NP2900W** ហើយចុច **Print**។




1 ជ្រើសម៉ាស៊ីន **MTC NP2900W**។

2 ចុច **Print**។


4.5 បោះពុម្ពឯកសារ៖ PDF, រូបភាព, Word, Excel

ចុច **Print a file** នៅផ្នាំង **Status** (ឬរូបតំណាងរបារម៉ឺនុយ → **Print a file…**) ហើយជ្រើសឯកសារ៖





1. ការមើលជាមុនសខ្មៅ ដូចក្រដាសដែលនឹងចេញមក។ ចុច ✓ លើទំព័រណាមួយ ដើម្បីរំលង ឬរក្សាវា។
2. ម៉ាស៊ីនបោះពុម្ព។ បើមានច្រើន អ្នកអាចជ្រើសច្រើនជាងមួយ។
3. ទំព័រទាំងអស់ សេស គូ ឬវាយចន្លោះទំព័រ។
4. ចំនួនច្បាប់ ខាងក្រោមគឺទំហំក្រដាស និងទិសដៅ។
5. **Print options**៖ ភាពដិត បង្រួមទំព័រគ្មានគែមឱ្យសម។ សម្រាប់ការបោះពុម្ពនេះតែប៉ុណ្ណោះ។
6. ចុច **Print**។

4.6 តាមដានការបោះពុម្ព និងការជូនដំណឹង



1. ម៉ាស៊ីនកំពុងបោះពុម្ពឯកសាររបស់អ្នក។
2. **Cancel**៖ បញ្ឈប់ការបោះពុម្ពនេះ។
3. **Printer queue**៖ ការបោះពុម្ពដែលកំពុងរង់ចាំ របស់អ្នក និងរបស់អ្នកដទៃ។





4. **≡**៖ ការបោះពុម្ពមិនទាន់ចប់របស់ Mac នេះ។
5. **Bell**៖ បានបោះពុម្ព អស់ក្រដាស ក្រដាសស្ទះ...

គន្លឹះ


ពេល Mac នេះបោះពុម្ព បង្ហួចបើកដោយខ្លួនឯង ដើម្បីឱ្យអ្នកតាមដាន ហើយលាក់ពេលរួច។ អ្នកអាចប្តូរនៅផ្ទាំង **Settings**។

4.7 ការបោះពុម្ពតាម USB


Mac មិននៅលើបណ្តាញរបស់ម៉ាស៊ីន ឬគ្មាន Wi-Fi៖ ភ្ជាប់ខ្សែ USB ដែលភ្ជាប់មកជាមួយម៉ាស៊ីនទៅ Mac។ គ្មានអ្វីត្រូវដំឡើងបន្ថែម៖ ម៉ាស៊ីន **MTC NP2900W** បោះពុម្ពតាមខ្សែ ហើយផ្ទាំង **Status** បង្ហាញ **Ready to print over USB** និង **USB cable: Connected**។

4.8 ការបោះពុម្ពពីខាងក្រៅ


នៅលើ Mac ដែលនៅលើបណ្តាញរបស់ម៉ាស៊ីន៖ ផ្ទាំង **Printer** រំកិលចុះទៅ **Printing from outside**។



1. បើក **Printing from outside**។
2. ចុច **Share this printer**។




3. ជ្រើសរយៈពេលដែលពួកគេអាចបោះពុម្ព។
4. ចុច **Create the QR code**។



5 ម្ចាក់ទៀតស្កេនកូដដោយកាមេរ៉ាទូរស័ព្ទ។ វាប្រើបានតែម្តង ក្នុងរយៈពេល 1 នាទី។

6 ឬចុច **Copy link** ហើយផ្ញើតំណក្នុងសារ ឬអ៊ីមែល។


នៅលើ Mac នៅកន្លែងផ្សេង៖ បើកតំណអញ្ជើញ ហើយកម្មវិធីនឹងស្នើបន្ថែមម៉ាស៊ីន។ ឬនៅផ្ទាំង **Printer**៖ ប្រអប់ **Current printer** → **Add a printer with an invitation link**៖




7 បិទភ្ជាប់តំណអញ្ជើញ ហើយចុច **Add**។

8 ឬ **Choose a picture of the QR code...** ដែលបានផ្ញើមកអ្នកក្នុងសារ។

4.9 ការកំណត់ និងបច្ចុប្បន្នភាព





1. **Printer in macOS**៖ ដំឡើងឡើងវិញ ឬដកម៉ាស៊ីន MTC NP2900W ចេញពី macOS (ត្រូវការពាក្យសម្ងាត់ Mac)។
2. **Open this window by itself**៖ រាល់ពេល Mac នេះបោះពុម្ព ឬតែពេលការបោះពុម្ពបរាជ័យ ឬម៉ាស៊ីនត្រូវការអ្នក។
3. **Print darkness**៖ ពី −5 (ស្រាលបំផុត) ដល់ +5 (ដិតបំផុត)។ ចុច **Save** នៅខាងក្រោម។
4. **Rename printer**៖ កុំព្យូទ័រ និងទូរស័ព្ទទាំងអស់ឃើញឈ្មោះថ្មី។
5. **Check for a new firmware now**។ ពេលមានកំណែថ្មី ផ្ទាំង **Printer** មានចំណុចពណ៌ស្វាយ៖ ចុច **Update** ហើយកុំបិទម៉ាស៊ីនរហូតដល់រួច។

គន្លឹះ

កម្មវិធីធ្វើបច្ចុប្បន្នភាពខ្លួនឯងពេលមានកំណែថ្មី បន្ទាប់មកចាប់ផ្តើមឡើងវិញ។

5

Android

កម្មវិធី MTC NP2900W សម្រាប់ទូរស័ព្ទ និងថេប្លេត Android 8.0 ឬថ្មីជាងនេះ។

5.1 ទាញយកកម្មវិធី

ស្កេនកូដ QR ខាងក្រោមដោយទូរសព្ទ Android ឬបើក **Google Play** ហើយស្វែងរក **MTC NP2900W**។ ជ្រើសកម្មវិធីដែលមានរូបតំណាងដូចក្នុងរូប អ្នកអភិវឌ្ឍ **Nam Phat Technology Co., Ltd** ហើយចុច **Install**។

NP

MTC NP2900W

Nam Phat Technology Co., Ltd


ស្កេនដើម្បីបើកនៅលើ Google Play

គន្លឹះ

ទូរសព្ទដែលគ្មាន Google Play៖ ទាញយកកម្មវិធីដំឡើងពី **mtcprinter.com → ផលិតផល → NP2900W**។ លើកដំបូងដែលដំឡើងពីកម្មវិធីរុករក Android នឹងសុំការអនុញ្ញាត៖ ចុច **Settings** បើក **Allow from this source** ត្រឡប់ក្រោយ ហើយចុច **Install**។

5.2 បើកកម្មវិធី ហើយជ្រើសម៉ាស៊ីនបោះពុម្ព

កម្មវិធីប្រើភាសារបស់ទូរស័ព្ទ។ លើកដំបូង ចុចផ្ទាំង **Printer**៖




1. ចុចប្រអប់ **Current printer**។
2. ចុចឈ្មោះម៉ាស៊ីនរបស់អ្នក។ គ្មានម៉ាស៊ីន៖ ទូរស័ព្ទត្រូវនៅលើបណ្តាញ Wi-Fi របស់ម៉ាស៊ីន។
3. **Ready to print over Wi-Fi**៖ អ្នកអាចបោះពុម្ពបាន។
4. **Print a file** (5.4)។

គន្លឹះ៖

លើកដំបូង កម្មវិធីសួរ **Show the printer status when you print**៖ ចុច **Allow** បន្ទាប់មកបើក **Display over other apps** ដើម្បីឱ្យអេក្រង់ស្ថានភាពបើកដោយខ្លួនឯងរាល់ពេលបោះពុម្ព។ អ្នកអាចប្តូរនៅផ្ទាំង **Settings**។

5.3 ការបោះពុម្ពពីកម្មវិធីផ្សេងៗ

ក្នុងកម្មវិធីដែលបង្ហាញឯកសារ (Chrome, Drive, Gmail...) ចុច ⋮ → **Print** (ឬ **Share** → **Print**)។ Android បើកអេក្រង់បោះពុម្ព៖




1. ចុចប្រអប់ម៉ាស៊ីនខាងលើ ហើយជ្រើស **MTC NP2900W - WIFI**។ បើគ្មាន៖ ចុច **All printers...**
2. ប្តូរចំនួនច្បាប់ ឬទំហំក្រដាសបើចាំបាច់ (ចុច ⌄) បន្ទាប់មកចុចប៊ូតុងមូល **Print**។

គន្លឹះ៖

គ្មាន **MTC NP2900W - WIFI** ក្នុងបញ្ជី៖ បើកផ្ទាំង **Settings** របស់កម្មវិធី។ បើវាបង្ហាញ **Print service is off** ចុច **Open print settings** ហើយបើក **MTC NP2900W**។

5.4 បោះពុម្ពឯកសារ៖ PDF, រូបភាព, Word, Excel

ចុច **Print a file** នៅផ្នាំង **Status** ហើយជ្រើសឯកសារនៅលើទូរស័ព្ទ។ ពីកម្មវិធីផ្សេង (Gmail, Files...)៖ ចុច **Share** → **MTC NP2900W**។




1. ការមើលជាមុនសខ្មៅ ដូចក្រដាសដែលនឹងចេញមក។ ចុច ✓ លើទំព័រណាមួយ ដើម្បីរំលង ឬរក្សាវា។
2. ម៉ាស៊ីនបោះពុម្ព។ បើមានច្រើន អ្នកអាចជ្រើសច្រើនជាងមួយ។
3. ទំព័រទាំងអស់ សេស ឬគូ ឬ **Choose pages** ដើម្បីវាយចន្លោះទំព័រ។
4. ចំនួនច្បាប់ ទំហំក្រដាស ទិសដៅ។
5. **Print options**៖ ភាពដិត បង្រួមទំព័រគ្មានគែមឱ្យសម។ សម្រាប់ការបោះពុម្ពនេះតែប៉ុណ្ណោះ។
6. ចុច **Print**។

គន្លឹះ

ឯកសារ Word និង Excel ត្រូវបានរៀបចំនៅលើទូរស័ព្ទផ្ទាល់ ហើយមិនត្រូវបានផ្ញើទៅណាទេ។


5.5 តាមដានការបោះពុម្ព និងការជូនដំណឹង




1. ម៉ាស៊ីនកំពុងបោះពុម្ពឯកសាររបស់អ្នក។
2. **Cancel**៖ បញ្ឈប់ការបោះពុម្ពនេះ។
3. **Printer queue**៖ ការបោះពុម្ពដែលកំពុងរង់ចាំ របស់អ្នក និងរបស់អ្នកដទៃ។
4. **≡**៖ ការបោះពុម្ពមិនទាន់ចប់របស់ទូរស័ព្ទនេះ។
5. **Bell**៖ បានបោះពុម្ព អស់ក្រដាស ក្រដាសស្ទះ...

5.6 ការបោះពុម្ពពីខាងក្រៅ

នៅលើទូរស័ព្ទដែលនៅលើបណ្តាញរបស់ម៉ាស៊ីន៖ ធ្នាំង **Printer** រំកិលចុះទៅ **Printing from outside**។






1. បើក **Printing from outside**។
2. ចុច **Share this printer**។
3. ជ្រើសរយៈពេលដែលពួកគេអាចបោះពុម្ព។
4. ចុច **Create the QR code**។




5. ម្នាក់ទៀតស្កេនកូដដោយកាមេរ៉ាទូរស័ព្ទ។ វាប្រើបានតែម្តង ក្នុងរយៈពេល 1 នាទី។
6. ឬចុច **Send link** ដើម្បីផ្ញើក្នុងសារ។

នៅលើទូរស័ព្ទនៅកន្លែងផ្សេង៖ ស្កេន QR code ដោយកាមេរ៉ា ហើយចុចតំណ កម្មវិធីបើក ហើយបន្ថែមម៉ាស៊ីន។ ឬក្នុងកម្មវិធី៖ ប្រអប់ **Current printer → Add a printer with an invitation link**៖



7. ស្កេន QR code នៅលើអេក្រង់ឧបករណ៍ដែលមានម៉ាស៊ីន។
8. ជ្រើសរូប QR code ដែលបានផ្ញើមកអ្នកក្នុងសារ។
9. បិទភ្ជាប់តំណអញ្ជើញដែលអ្នកបានចម្លង។

5.7 ការកំណត់ និងបច្ចុប្បន្នភាព



1. **Open print settings**៖ បើកសេវាបោះពុម្ពរបស់ Android សម្រាប់ MTC NP2900W (5.3)។
2. បើកអេក្រង់ស្ថានភាពដោយខ្លួនឯងរាល់ពេលទូរស័ព្ទនេះបោះពុម្ព។
3. **Print darkness**៖ ពី −5 (ស្រាលបំផុត) ដល់ +5 (ដិតបំផុត)។ ចុច **Save** នៅខាងក្រោម។
4. **Rename printer**៖ កុំព្យូទ័រ និងទូរស័ព្ទទាំងអស់ឃើញឈ្មោះថ្មី។
5. **Check for a new firmware now**។ ពេលមានកំណែថ្មី ផ្ទាំង **Printer** មានចំណុចពណ៌ស្វាយ៖ ចុច **Update** ហើយទុកកម្មវិធីឱ្យបើករហូតដល់រួច។

គន្លឹះ

ពេលមានកំណែថ្មី កម្មវិធីបង្ហាញ **Update required**៖ ចុច **Update now**។ ការបោះពុម្ពដែលកំពុងដំណើរការនៅតែបន្តរហូតចប់។


6

iPhone និង iPad

កម្មវិធី MTC NP2900W សម្រាប់ iPhone និង iPad ដែលប្រើ iOS 16 ឬថ្មីជាងនេះ។ នៅលើ iPad ជំហានដូចនៅលើ iPhone។


6.1 ទាញយកកម្មវិធី

បើក **App Store** ហើយស្វែងរក **MTC NP2900W**។ ជ្រើសកម្មវិធីដែលមានរូបតំណាងខាងក្រោម អ្នកអភិវឌ្ឍ **Thanh Nam Nguyen** ហើយចុច **Get**។



6.2 បើកកម្មវិធី ហើយជ្រើសម៉ាស៊ីនបោះពុម្ព

កម្មវិធីប្រើភាសារបស់ iPhone។ លើកដំបូង ចុចផ្ទាំង **Printer**៖



1. ចុចប្រអប់ **Current printer**។


2. ចុចឈ្មោះម៉ាស៊ីនរបស់អ្នក។ គ្មានម៉ាស៊ីន៖ iPhone ត្រូវនៅលើបណ្តាញ Wi-Fi របស់ម៉ាស៊ីន។
3. **Ready to print over Wi-Fi**៖ អ្នកអាចបោះពុម្ពបាន។
4. **Print a file** (6.4)។

គន្លឹះ

លើកដំបូង iPhone សុំ **send notifications** និង **find devices on your local network**៖ ចុច **Allow** ទាំងពីរ។ បើបានចុច Don't Allow៖ **Settings** → **MTC NP2900W** → បើក **Local Network**។

6.3 ការបោះពុម្ពពីកម្មវិធីផ្សេងៗ

iPhone មិនអនុញ្ញាតឱ្យម៉ាស៊ីនផ្សេងចូលក្នុងប៊ូតុង **Print** របស់វាទេ។ ក្នុងកម្មវិធីដែលបង្ហាញឯកសារ (Photos, Files, Safari...) ចុច **Share** បន្ទាប់មក **MTC NP2900W**៖




អេក្រង់បោះពុម្ពនៃ 6.4 បង្ហាញ៖ ជ្រើសទំព័រ និងចំនួនច្បាប់ បន្ទាប់មកចុច **Print**។ ទុកវាឱ្យបើករហូតដល់ការបោះពុម្ពត្រូវបានធ្វើ។

គន្លឹះ

គ្មាន **MTC NP2900W** ក្នុងជួរកម្មវិធី៖ អូសជួរទៅឆ្វេង ចុច **More** ហើយជ្រើស **MTC NP2900W**។

6.4 បោះពុម្ពឯកសារ៖ PDF, រូបភាព, Word, Excel

ផ្នាំង **Status** → **Print a file** → **Files (PDF, photos, Word, Excel)** ឬ **Photos** បន្ទាប់មកជ្រើសឯកសារ៖




1. ការមើលជាមុនសខ្មៅ ដូចក្រដាសដែលនឹងចេញមក។ ចុច ✓ លើទំព័រណាមួយ ដើម្បីរំលង ឬរក្សាវា។
2. ម៉ាស៊ីនបោះពុម្ព។ បើមានច្រើន អ្នកអាចជ្រើសច្រើនជាងមួយ។
3. ទំព័រទាំងអស់ សេស ឬគូ ឬ **Choose pages** ដើម្បីវាយចន្លោះទំព័រ។
4. ចំនួនច្បាប់ ទំហំក្រដាស ទិសដៅ។ នៅខាងក្រោម៖ **Print options** (ភាពដិត បង្រួមទំព័រគ្មានគែមឱ្យសម) សម្រាប់ការបោះពុម្ពនេះ។
5. ចុច **Print**។

គន្លឹះ

ឯកសារ Word និង Excel ត្រូវបានរៀបចំនៅលើ iPhone ផ្ទាល់ ហើយមិនត្រូវបានផ្ញើទៅណាទេ។


6.5 តាមដានការបោះពុម្ព និងការជូនដំណឹង




1. ម៉ាស៊ីនកំពុងបោះពុម្ពឯកសាររបស់អ្នក។
2. **Cancel**៖ បញ្ឈប់ការបោះពុម្ពនេះ។
3. **Printer queue**៖ ការបោះពុម្ពដែលកំពុងរង់ចាំ របស់អ្នក និងរបស់អ្នកដទៃ។
4. **≡**៖ ការបោះពុម្ពមិនទាន់ចប់របស់ iPhone នេះ។
5. **Bell**៖ បានបោះពុម្ព អស់ក្រដាស ក្រដាសស្ទះ...


6.6 ការបោះពុម្ពពីខាងក្រៅ

នៅលើ iPhone ដែលនៅលើបណ្តាញរបស់ម៉ាស៊ីន៖ ផ្ទាំង **Printer** រំកិលចុះទៅ **Printing from outside**។






1. បើក **Printing from outside**។
2. ចុច **Share this printer**។
3. ជ្រើសរយៈពេលដែលពួកគេអាចបោះពុម្ព។
4. ចុច **Create the QR code**។




5. ម្ជាក់ទៀតស្កេនកូដដោយកាមេរ៉ាទូរស័ព្ទ។ វាប្រើបានតែម្តង ក្នុងរយៈពេល 1 នាទី។
6. ឬចុច **Send link** ដើម្បីផ្ញើក្នុងសារ។

នៅលើទូរស័ព្ទនៅកន្លែងផ្សេង៖ ស្កេន QR code ដោយកម្មវិធីកាមេរ៉ា ហើយចុចតំណ កម្មវិធីបើក ហើយស្នើបន្ថែមម៉ាស៊ីន។ ឬក្នុងកម្មវិធី៖ ប្រអប់ **Current printer** → **Add a printer with an invitation link**៖



7. ស្កេន QR code នៅលើអេក្រង់ឧបករណ៍ដែលមានម៉ាស៊ីន។
8. ជ្រើសរូប QR code ដែលបានផ្ញើមកអ្នកក្នុងសារ។
9. បិទភ្ជាប់តំណអញ្ជើញដែលអ្នកបានចម្លង។

6.7 ការកំណត់ និងបច្ចុប្បន្នភាព



1. **How to print**៖ រំលឹកពីរបៀបបោះពុម្ពពីកម្មវិធីផ្សេង (6.3)។
2. **Notify me**៖ រាល់ពេល iPhone នេះបោះពុម្ព ឬតែពេលការបោះពុម្ពបរាជ័យ ឬម៉ាស៊ីនត្រូវការអ្នក។
3. **Print darkness**៖ ពី −5 (ស្រាលបំផុត) ដល់ +5 (ដិតបំផុត)។ ចុច **Save** នៅខាងក្រោម។
4. **Rename printer**៖ កុំព្យូទ័រ និងទូរស័ព្ទទាំងអស់ឃើញឈ្មោះថ្មី។
5. **Check for a new firmware now**។ ពេលមានកំណែថ្មី ផ្ទាំង **Printer** មានចំណុចពណ៌ស្វាយ៖ ចុច **Update** ហើយទុកកម្មវិធីឱ្យបើករហូតដល់រួច។

គន្លឹះ

ពេលមានកំណែថ្មីនៅ App Store កម្មវិធីបង្ហាញ **Update required**៖ ចុច **Update now** ហើយធ្វើបច្ចុប្បន្នភាពនៅ App Store។


7

ឯកសារយោង និងការដោះស្រាយបញ្ហា

ការបោះពុម្ពដោយគ្មាន Wi-Fi ការិយាល័យ ពេលមានបញ្ហា ជំនួយបន្ថែម។

7.1 ការបោះពុម្ពដោយគ្មាន Wi-Fi ការិយាល័យ

ម៉ាស៊ីនមានបណ្តាញ Wi-Fi ផ្ទាល់ខ្លួនសម្រាប់ពេលគ្មានរ៉ោតទ័រ Wi-Fi។ ឈ្មោះរបស់វាគឺឈ្មោះម៉ាស៊ីនបន្តដោយ **Direct** ឧទាហរណ៍ **Accounting Direct** (ម៉ាស៊ីនមិនទាន់មានឈ្មោះ៖ **NP2900W-XXXX Direct**)។ ពាក្យសម្ងាត់៖ **1234567890**។



1. នៅលើទូរស័ព្ទ ឬកុំព្យូទ័រ ចូលទៅ Wi-Fi ជ្រើសបណ្តាញនោះ វាយពាក្យសម្ងាត់ បន្ទាប់មកបើកកម្មវិធី MTC ហើយបោះពុម្ពដូចធម្មតា។ រហូតដល់ 4 ឧបករណ៍ក្នុងពេលតែមួយ។

7.2 ពេលមានបញ្ហា

- **គ្មានបណ្តាញ NP2900W-XXXX៖** ម៉ាស៊ីនធ្លាប់ត្រូវបានរៀបចំលើ Wi-Fi រួចហើយ (បណ្តាញរបស់វាឥឡូវគឺ … Direct)។ ដើម្បីរៀបចំម្តងទៀត៖ សង្កត់ប៊ូតុង PAPER ជាប់ 8 វិនាទី រួចលែង។
- **ទំព័ររៀបចំមិនបើកដោយខ្លួនឯង៖** បើកកម្មវិធីរុករក ហើយចូលទៅ 192.168.4.1។
- **ភ្លើងបៃតងនៅតែភ្លឹបយឺតក្រោយ Connect៖** ពាក្យសម្ងាត់ Wi-Fi ខុស ឬម៉ាស៊ីននៅឆ្ងាយពីរ៉ោតទ័រពេក។ ធ្វើជំពូក 2 ម្តងទៀត។
- **កម្មវិធីរកមិនឃើញម៉ាស៊ីន៖** ឧបករណ៍ និងម៉ាស៊ីនត្រូវនៅលើបណ្តាញ Wi-Fi តែមួយ (មិនមែនបណ្តាញភ្ញៀវ)។ នៅលើ iPhone៖ Settings → MTC NP2900W → បើក Local Network។
- **រ៉ោតទ័រថ្មី ឬពាក្យសម្ងាត់ Wi-Fi ថ្មី៖** សង្កត់ប៊ូតុង PAPER ជាប់ 8 វិនាទី លែង ហើយធ្វើជំពូក 2 ម្តងទៀត។
- **ការបោះពុម្ពស្រាលពេក ឬដិតពេក៖** កែ **Print darkness** ក្នុង Settings របស់កម្មវិធី ឬក្នុង Print options ពេលបោះពុម្ពឯកសារ។
- **គ្មានទំព័រសាកល្បងក្រោយសង្កត់ PAPER 3 វិនាទី ហើយភ្លើងក្រហមភ្លឹបជាក្រុម៖** ម៉ាស៊ីនកំពុងពិនិត្យខ្លួនឯង។ រាប់ចំនួនដងភ្លឹបក្នុងក្រុមមួយ ហើយប្រាប់អ្នកចែកចាយ។

7.3 ជំនួយបន្ថែម

ទាញយកកម្មវិធី
កុំព្យូទ័រ៖ mtcprinter.com → ផលិតផល → NP2900W
ទូរស័ព្ទ៖ ស្វែងរក “MTC NP2900W” នៅ App Store ឬ Google Play។

សំណួរញឹកញាប់
mtcprinter.com → ផលិតផល → NP2900W

ការធានា
ទាក់ទងហាងដែលអ្នកបានទិញម៉ាស៊ីន។

ជំនួយ
អ្នកចែកចាយរបស់អ្នក ឬ support@mtcprinter.com។ ត្រៀមលេខសៀរៀលពីស្លាកនៅខាងក្រោយម៉ាស៊ីន។

MTC NP2900W គឺជាឈ្មោះផលិតផលរបស់ MTC Dongguan Baijie Trading Co., Ltd.។ Windows, macOS, iPhone, iPad, App Store, Android និង Google Play គឺជាពាណិជ្ជសញ្ញារបស់ម្ចាស់។ អេក្រង់សម្រាប់ជាឧទាហរណ៍ ហើយអាចខុសបន្តិចនៅលើឧបករណ៍របស់អ្នក។ © 2026 MTC · 3.0 · 10/2026